មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំខប់សែលប្រ៉ូម តំបន់ទី ១

## យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

ថ្ងៃព្រហស្បត្តិ៍ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៥

ក្រុង ព្រះសីហនុ

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

១. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម ដោយលោក **ឱក សេរី សោភក្តិ៍** ទីប្រឹក្សានិងជាអ្នកសម្របសម្រួលកិច្ចប្រជុំខប់សែល នៃវិទ្យាស្ថាន CDRI

២. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោតថ្លែងដោយលោក **ហ៊ួត ផុន** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតក្រុងព្រះសីហនុ

៣. មតិរបស់អ្នកចូលរួមបង្ហាញពីការប្រឈមទាំងឡាយនៅក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទក្រុងព្រះសីហនុ

៤. សេចក្តីផ្សេងៗ

### ១. បទអន្តរាគមន៍ស្តីពីយន្តការខប់សែលប្រ៉ម ដោយលោក ឱក សេរី សោភក្តិ៍ ទីប្រឹក្សា និងជាអ្នកសម្របសម្រួលកិច្ចប្រជុំ ខប់សែល នៃវិទ្យាស្ថាន CDRI

លោក **ឱក សេរី សោភក្តិ៍** ទីប្រឹក្សានៃវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និងជាអ្នកសម្របសម្រួល កិច្ចប្រជុំខប់សែលបានស្វាគមន៍សមាជិកអង្គប្រជុំដែលបានចំណាយពេលដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ ខប់សែលប្រ៉ម នៅតំបន់ទី១ នៃយន្តការខប់សែលដំណាក់កាលទី ២ នេះ និង បានជំរាបជូនអង្គប្រជុំថា យន្តការខប់សែលដំណាក់កាល ទី ២ ដែលទទួលបានការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) នៅទីក្រុងញ៉ូវយ៉កមានបួនរចនាសម្ព័ន្ធ ដូចជា ទី ១ ការប្រជុំខប់សែលខម (ខប់សែលប្រជុំស្នូល) ធ្វើឡើងសំរាប់អ្នកឯកទេសបោះឆ្នោតប្រមាណ ២០ នាក់មកពី គជប គណបក្សនយោបាយធំៗ ក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថ នគរបាលជាតិ និងអង្គការសង្គមស៊ីវិល ដោយធ្វើការប្រជុំ ម្តងក្នុង ១ខែ ។ ទី ២ ការប្រជុំខប់សែលឡឹម ដែលមានអ្នកចូលរួមប្រហែល ៧០ នាក់ មកពីអង្គការយុវជន អង្គការស្ត្រី កម្មករសហជីព ដោយធ្វើការប្រជុំ៣ ខែម្តង។ ទី ៣ ការប្រជុំខប់សែលប្រ៉ម (ការប្រជុំខប់សែលនៅតាមខេត្ត)ដែលនឹងធ្វើនៅគ្រប់ខេត្តក្រុងចំនួន ២៣ ក្នុងរយៈពេលបីឆ្នាំខាងមុខនេះ ។ ទី ៤ ការប្រជុំខប់សែលជាមួយសារព័ត៌មាន ដែលនឹងរៀបចំប្រជុំជាមួយបណ្តាញ សារព័ត៌មានដោយឡែកដើម្បីផ្សព្វផ្សាយជូនសារធារណៈជនឱ្យបានជ្រួតជ្រាបអំពីដំណើរការនេះ ។ គោលបំណងសំខាន់នៃយន្តការខប់សែល គឺបង្កើតឱ្យមានការជឿទុកចិត្តគ្នាដើម្បីពិភាក្សាដោះស្រាយបញ្ហាដែលកើតមានទាក់ទងនិងការងារបោះឆ្នោតទាំងបីខាងមុខនេះ ប្រកបដោយការគោរព យោគយល់ និង ឱ្យតំលៃគ្នាទៅវិញទៅមកលើទស្សនៈ គំនិតរបស់ខ្លួន និងអ្នកដទៃ ដើម្បីឈានទៅរកការពិភាក្សាប្រកបដោយជោគជ័យ និងអាចកសាងបានវប្បធម៌ពិភាក្សាគ្នាទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។ លោកក៏បានជំរាប ជូនផងដែរពីបែបបទនៃការប្រជុំខប់សែលទាំងអស់ដោយរួមមានទាំងការថតសំលេងទុកដើម្បីធ្វើកំណត់ហេតុ រាល់កំណត់ហេតុទាំងអស់នឹងត្រូវផ្ញើថ្វាយព្រះមហាក្សត្រ និងជូនថ្នាក់ដឹកនាំកំពូលៗ នៃរដ្ឋសភា និង រាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គម ស៊ីវិលជាតិ និង អន្តរជាតិ អង្គទូតនានានៅកម្ពុជាឯកឧត្តមអភិបាលខេត្ត អភិបាលរង ក្រុមប្រឹក្សាឃុំទូទាំងប្រទេស ។ លោកបានលើកយកគោលបំណងធំៗ ៣ របស់ យន្តការខប់សែលប្រ៉ម តំណាក់កាលទី២ នេះមានដូចជាគោលដៅធំទី១ ធ្វើយ៉ាងណាយុទ្ធនាការជាមួយរដ្ឋាភិបាលជាពិសេសក្រសួង មហាផ្ទៃ និងឯកឧត្តមអភិបាលខេត្តទាំងអស់ធ្វើឱ្យបញ្ហាអត្តសញ្ញាណប័ណ្ណនេះឈប់ជាបញ្ហាទៀត ឱ្យប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ ទទួលបានអត្តសញ្ញាណប័ណ្ណគ្រប់គ្នាតែម្តង ។ មានដំណឹងមកថា **UNDP** មានគំរោងនឹងជួយជាថវិកា តែឥឡូវកំពុងតែសិក្សាលំអិត ។ គោលដៅធំទី ២ គឺធ្វើឱ្យយន្តការនៃការចុះឈ្មោះបោះឆ្នោតក្លាយជាយន្តការប្រចាំថ្ងៃសំរាប់ប្រជាពលរដ្ឋនៅក្នុងភូមិទាំងអស់កុំឱ្យការ

ចុះឈ្មោះបោះឆ្នោតគឺជាបញ្ហាទៀតជាពិសេសក្នុងរយៈពេល ៩ ខែ ត្រៀមនិង ១ខែ ការចុះឈ្មោះមែនទែន ។ គោលដៅធំទី ៣ ទាក់ទងនឹងក្រសួងមានសមត្ថកិច្ចផ្ទាល់ធ្វើឱ្យយន្តការនៃការបោះឆ្នោត បានប្រព្រឹត្តទៅគ្រប់ពេលវេលាគ្រប់យន្តការបោះឆ្នោតនៅក្នុងសភាពមិនភ័យខ្លាចហើយគណបក្សនយោបាយក៏អាចធ្វើសកម្មភាពទៅតាមលក្ខណៈច្បាប់ ដោយគ្មានការគំរាមកំហែង ដោយគ្មានការបំភិតបំភ័យ ពីអាជ្ញាធរមូលដ្ឋាន តាំងពីភូមិឃុំ រហូតដល់ស្រុកខេត្ត ។

## ២. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោតថ្លែងដោយលោក ហ៊ួត ផុន ប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការរៀបចំការបោះឆ្នោត ក្រុងព្រះសីហនុ

លោកបានលើកពីការបោះឆ្នោតនៅកម្ពុជា ៤ លើកកន្លងមកនេះ មានលើកទី១ នៅថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ ១៩៩៣ រៀបចំដោយអង្គការសហប្រជាជាតិ ដែលមានប្រជាពលរដ្ឋចូលរួមបោះឆ្នោតជាង ៤ លាននាក់ លើកទី ២ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ១៩៩៨ មានប្រជាពលរដ្ឋចូលរួមបោះឆ្នោត ៥.៣៩៥.៥៩៥ នាក់លើកទី ៣ នៅឆ្នាំ ២០០២ ប្រជាពលរដ្ឋបានចូលរួមបោះឆ្នោតមាន ៥.០១៩.៣០៧ នាក់លើកទី៤នៅ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៣ ប្រជាពលរដ្ឋបានចូលរួមបោះឆ្នោតមាន ៦.០៣៤.៨៣៤ នាក់។ ចាប់ពីឆ្នាំ ១៩៩៨ គជប បានចាប់ផ្តើមរៀបចំការបោះឆ្នោតនេះដោយខ្លួនឯងដំបូង ដោយមានជំនាញការអន្តរជាតិ មានមកពីអង្គការសហប្រជាជាតិ សហគមន៍នានាជួយផ្នែកបច្ចេកទេស ដូចជាផ្នែកច្បាប់ ផ្នែករដ្ឋបាល និងបច្ចេកទេសទូទៅ ។ ជាធម្មតាការបោះឆ្នោតនីមួយៗគជប តែងតែអនុវត្តតាមច្បាប់ដែលអនុម័តពីរដ្ឋសភាជានិច្ច ដោយយកច្បាប់នេះជាគោល តាក់តែងរៀបចំនីតិវិធីដើម្បីអនុវត្តការបោះឆ្នោតទូទាំងប្រទេស និងមានសហការជាមួយគ្រប់គណបក្សនយោបាយ គ្រប់អង្គការមិនមែនរដ្ឋាភិបាល អ្នកឯកទេសច្បាប់នានា និងអង្គការអន្តរជាតិមួយចំនួន ដើម្បីធ្វើឱ្យនីតិវិធី បទបញ្ជានេះស្របទៅតាមច្បាប់ ដូចជាការប្រជុំរបស់ខប់សែលនេះជាដើម ដែលមានអ្នកចូលរួមជាច្រើនបានលើកឡើងមតិយោបល់ល្អដើម្បីកែតំរូវនូវចំនុចដែលខ្វះខាត ។ លោកបានលើកបញ្ជាក់ថាការបោះឆ្នោតមាន ៥ តំណាក់កាលដើម្បីឱ្យអង្គប្រជុំពិចារណាទៅលើចំនុចណា ដែលអាចនាំឱ្យមានទំនាស់ និងស្នើឱ្យជួយលើកជាមតិយោបល់ដើម្បីជួយបង្ការទំនាស់នេះកុំឱ្យមានតទៅទៀត ។ នៅក្នុងដំណាក់កាលនីមួយៗនៃ ការរៀបចំការបោះឆ្នោត ជាដំបូងតំរូវឱ្យមានការជ្រើសរើសមន្ត្រីតាមខេត្តដែលមានសមត្ថភាពដឹកនាំគ្រប់គ្រងការងារបោះឆ្នោត ស្គាល់ភូមិសាស្ត្រទូលំទូលាយ មានសច្ចៈយុត្តិធម៌ និងមានឆន្ទៈក្នុងការងារបោះឆ្នោត ។ ជំហានបន្ទាប់គឺការបណ្តុះបណ្តាលអំពីបទបញ្ជា នីតិវិធី បែបបទរដ្ឋបាល សម្ភារៈបច្ចេកទេសដើម្បីផ្សព្វផ្សាយបន្តទៅដល់ភូមិ ឃុំ ។ ការអប់រំដល់សាធារណៈជនឱ្យទូលំទូលាយ តាមរយៈ បដា វិទ្យុ ទូរទស្សន៍ មេគ្រូ ផ្ទាំងរូបភាពធំៗ កាសែត រឿងខ្លីៗ រឿងកំប្លែងដែលងាយយល់អនុវត្ត ហើយការអប់រំនេះនៅមានការខ្វះចន្លោះមួយចំនួន ។

តំណាក់កាល ទី២ ការចុះឈ្មោះអ្នកបោះឆ្នោត ដែលចាំបាច់ត្រូវធ្វើការដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ។ កន្លងមកលោកបានពិនិត្យឃើញថាឆន្ទៈរបស់ប្រជាពលរដ្ឋក្នុងការចូលរួម ចុះឈ្មោះនេះយ៉ាងខ្លាំង រហូតដល់ ៧-៨ ម៉ឺន នាក់ ក្នុងរយៈពេលខ្លី ។ ការលំបាករបស់ប្រជាពលរដ្ឋ គឺត្រូវបំពេញលក្ខខ័ណ្ឌដូចជាឈ្មោះអត្តសញ្ញាណដែលបញ្ជាក់សញ្ជាតិ អាយុ ទីលំនៅ ព្រោះប្រជាពលរដ្ឋភាគច្រើនពុំមានឯកសារយោងទាំងអស់នោះទេ ដែលចំនុចនេះយើងគួរពិចារណាឱ្យបានច្បាស់លាស់ឡើងវិញ ។ ជួនកាលការចុះឈ្មោះនេះជួបការលំបាក ដោយសារប្រជាពលរដ្ឋមកច្រើនពេកក្នុងពេលតែមួយ ធ្វើឱ្យចុះឈ្មោះនោះមិនទាន់មួយលើកជាពីរលើក ធ្វើឱ្យធុញទ្រាន់មិនចង់ធ្វើទៀត ។ ចំនុចនេះតើគួរមានមធ្យោបាយអ្វីដើម្បីជួយជំរុញឱ្យបានចុះឈ្មោះគ្រប់ៗគ្នា ។ យន្តការនៃការចុះឈ្មោះបោះឆ្នោតនេះរាប់ទាំងរយៈពេលនៃការចុះឈ្មោះ ពិនិត្យបញ្ជីឈ្មោះ បញ្ជីដំបូង បណ្តឹងតវ៉ា បណ្តឹងជំទាស់ និងបញ្ជីផ្លូវការ ។ ការងារចុះ

ឈ្មោះមានសារៈប្រយោជន៍ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត បើស្រលាញ់គណបក្សនយោបាយណា ស្រលាញ់ជាតិយ៉ាងណាក៏ដោយ បើអត់បានចុះឈ្មោះមានន័យថាអត់មានសិទ្ធិទាំងអស់ ។ តំណាក់កាលទី៣ ការឃោសនារបស់គណបក្ស ដែលធ្វើស្របតាមគោលនយោបាយរបស់ខ្លួន និងអនុវត្តតាមក្រមសីលធម៌របស់គណបក្ស ។ បើគណបក្សនយោបាយ ឃោសនាទៅតាមក្រមសីលធម៌ទំនាស់មិនអាចកើតមានទេ ។ ប៉ុន្តែការអនុវត្តន៍កន្លងមកមានគណបក្សមួយចំនួន មិនព្រមគោរពក្រមសីលធម៌នេះទេ តែក្រោយៗមក មានការប្រកាន់ និងគោរពក្រមនេះល្អប្រសើរ ។ តំណាក់កាលទី៤ ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ដែលនៅក្នុងតំណាក់កាលនេះតែងតែជួបបញ្ហាស្មុគស្មាញ ។ គជប ចេញសេចក្តីណែនាំមួយថា នៅពេលបោះឆ្នោត កាលណាមានព្រឹត្តិការណ៍អ្វីមិនប្រក្រតី ត្រូវតែអញ្ជើញគ្រប់គណបក្សនយោបាយ រដ្ឋអំណាចគ្រប់ជាន់ថ្នាក់មកជួបជុំគ្នាដើម្បីដោះស្រាយ ជៀសវាងការខុសឆ្គងនេះកាន់តែធ្ងន់ទៅធ្ងន់ទៅៗ ហើយការអនុវត្តកន្លងមក PEC មិនដែលបណ្តោយឱ្យការខុសឆ្គងនេះធ្ងន់ទៅទេ គឺកាលណាឃើញមានភាពមិនប្រក្រតីបន្តិចបន្តួច អញ្ជើញមកភ្លាមដើម្បីពិភាក្សារកដំណោះស្រាយឱ្យទាន់ពេលវេលា ។ ឥឡូវនេះមានសេចក្តីណែនាំ របស់គជប មួយទៀតដែលកំណត់ថាគ្រប់តំណាក់កាល បើមានភាពមិនប្រក្រតី ត្រូវតែអញ្ជើញគ្រប់គណបក្សនយោបាយ រដ្ឋអំណាចដែលពាក់ព័ន្ធ មកចូលរួមដើម្បីដោះស្រាយពិចារណាជាមួយគ្នា ។ ចំនុចនេះមិនទាន់មានបញ្ហានៅឡើយទេ ។ ចំពោះការរាប់សន្លឹកឆ្នោត និងសរុបនៅក្រុង PEC អញ្ជើញប្រធានគណបក្ស ឬតំណាងគណបក្សជាន់ខ្ពស់ត្រួតពិនិត្យលទ្ធផលទាំងអស់គ្នា ហើយកាលណាបានលទ្ធផលយ៉ាងណាសូមអស់លោកចុះហត្ថលេខាទទួលស្គាល់លទ្ធផល ។ ការលំបាកនៅពេលបោះឆ្នោតគឺគ្រាន់តែថាប្រជាពលរដ្ឋសំរុកមកនៅម៉ោងដំបូងធ្វើឱ្យមានការកកស្ទះ ត្រូវឈរតំរង់ជួរគ្នាជាពីរជួរ និង រងចាំយូរមានអ្នកខ្លះត្រលប់ទៅផ្ទះវិញព្រោះរវល់ធ្វើស្រែ នេសាទត្រី និង លក់ដូរ ដោយមិនបានបោះឆ្នោតឡើយ ដែលនេះជាការមួយគួរឱ្យសោកស្តាយ ។ ការលំបាកមួយ ទៀតនោះគឺប្រជាពលរដ្ឋមិនចេះអក្សរ នៅពេលគាត់ពិនិត្យបញ្ជីឈ្មោះចុងក្រោយគាត់ថារកឈ្មោះមិនឃើញ រួចគាត់រាយការណ៍ ថាបាត់ឈ្មោះ ។

លោក **ឱក សេរី សោភក្តិ៍** បានកោតសរសើរលោកប្រធាន PEC ដែលបានលើកឡើងដោយត្រង់ៗ អត់លាក់ទុកក្នុងចិត្ត និងស្នើសុំឱ្យអង្គប្រជុំចូលរួមរកដំណោះស្រាយទាំងអស់គ្នា ។ ការលើកឡើងដោយត្រង់នេះកំរមានណាស់នៅក្នុងសង្គមខ្មែរ ព្រោះតែការរក្សាមុខមាត់នៅក្នុងសង្គម ពោលគឺពេលខុសមិនងាយទទួលថាខុសទេ ទាល់ច្រកមិនងាយថាទាល់ច្រកទេ សុខចិត្តពួនស្រែកមិននិយាយចំពោះមុខគេឡើយដែលនេះធ្វើឱ្យមានការលំបាកក្នុងការរកដំណោះស្រាយ ។ នៅក្នុងសង្គមកាលណាមានការនិយាយដោយត្រង់ៗនេះ ធ្វើឱ្យមានការជឿនលឿន ។

លោក **ឱម សុផល** សមាជិកក្រុមប្រឹក្សាឃុំ គណបក្សសមរង្ស៊ី ក្រុងព្រះសីហនុ បានលើកឡើងថាការបោះឆ្នោតកន្លងមករាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងចំណាយថវិការយ៉ាងសន្ធឹកសន្ធាប់ ដើម្បីដំណើរការនៃការបោះឆ្នោតនាំទៅរកលទ្ធិប្រជាធិបតេយ្យយ៉ាងពិតប្រាកដ ហើយអង្គការនានាក៏បានជួយខ្នះខ្នែង ហើយស្ថាប័នជំនាញ NEC PEC CEC ក៏ខិតខំខ្នះខ្នែងណាស់ ជាពិសេស PEC ក្រុងក៏បានខ្នះខ្នែងដែលនាំឱ្យមិនសូវមានទំនាស់ទេ លើបញ្ហាផ្សេងៗឃើញថាមានការល្អប្រសើរនិងការរៀបរយ បង្កលក្ខណៈឱ្យការបោះឆ្នោតប្រព្រឹត្តិទៅបានល្អប្រសើរ តែទន្ទឹមនឹងនោះក៏មានចំនុចខ្វះខាតខ្លះ ដូចជាការផ្សព្វផ្សាយ ដែលធ្វើមិនបានដល់តាមផ្ទះប្រជាពលរដ្ឋ ដែលនៅក្នុងជ្រៅធ្វើឱ្យគាត់មិនបានដឹង និងមិនបានចាប់អារម្មណ៍លើការបោះឆ្នោតថាមានអត្ថន័យ មានតម្លៃយ៉ាងម៉េចនោះទេ ។ ការផ្សព្វផ្សាយក៏នៅមានការខ្វះខាតមួយចំនួនដែរ ឧបមាថាដូចការឃោសតាមរថយន្ត អ្នកបើកបរបើកលឿនដែលធ្វើឱ្យប្រជាពលរដ្ឋស្តាប់ន័យមិនបាន ។ គួរតែផ្សាយនៅកន្លែងមួយឱ្យបានយូរដើម្បីឱ្យប្រជាពលរដ្ឋស្តាប់បានខ្លឹមសារនៃការចុះឈ្មោះ

បោះឆ្នោត ហើយការផ្សព្វផ្សាយតាមទូរទស្សន៍គឺជារឿងល្អប្រសើរ ។ កន្លែងចុះឈ្មោះផ្សេង ការិយាល័យបោះឆ្នោតផ្សេងក៏ធ្វើឱ្យប្រជាពលរដ្ឋភាគច្រើនមិនបានទៅបោះឆ្នោតដែរ សំណូមពរឱ្យថាការចុះឈ្មោះ និងការិយាល័យបោះឆ្នោត កុំឱ្យមានការប្រែប្រួលខ្លាំងឬក៏ឃ្លាតឆ្ងាយគ្នាខ្លាំងពេក ។ ការផ្លាស់ប្តូរទីតាំងនេះក៏បង្កការលំបាកដែរឧបមាថាគាត់ធ្លាប់បោះនៅផ្សារលើស្រាប់តែពេលបោះឆ្នោតបន្តទៀតទៅបោះឆ្នោតនៅកន្លែងផ្សេង ដោយមិនកំណត់ពេលវេលា ឬក៏ជូនព័ត៌មានឱ្យច្បាស់លាស់ ។ ទាក់ទងនឹងម៉ោងបញ្ចប់នៅពេលបោះឆ្នោតត្រឹមម៉ោង ១៥:០០ លោកស្នើសុំថាគួរតែបញ្ចប់ ត្រឹមម៉ោង ១៦:០០ ព្រោះប្រជាពលរដ្ឋជាប់រវល់ធ្វើស្រែធ្វើចំការប្រជានេសាទ ។

លោក **សំ សំអាត** នាយខុទ្ទកាល័យសាលាក្រុងព្រះសីហនុ បានជូនយោបល់ទៅដល់ក្នុងអង្គប្រជុំខប់សែលថាគួរតែអញ្ជើញតំណាងអាជ្ញាធរក្រុងចូលរួម ដើម្បីឱ្យមានគ្រប់បណ្តាស្ថាប័ន ហើយដែលលោកមកនេះមកនេះគឺមិនមែនតំណាងអាជ្ញាធរក្រុងគឺក្នុងនាមជានាយខុទ្ទកាល័យសាលាក្រុងក៏ដូចជាប្រធានមន្ទីរមួយចំនួនដែរ ។

លោក **ឱក សេរី សោភក្តិ** បានទទួលស្គាល់ថានេះជាចំនុចខ្វះខាតនៃការរៀបចំរបស់លេខាធិការដ្ឋានខប់សែលមែន ។

លោក **សំ សំអាត** បានឱ្យយោបល់ក្នុងនាមជាអ្នកចូលរួមថានៅក្នុងកិច្ចប្រជុំខប់សែលនេះ គួរពិភាក្សាគ្នារកដំណោះស្រាយសំរាប់ ភាពទ័លច្រកទាំងឡាយដែលបានលើកឡើងនេះជាការល្អប្រសើរ ជាពិសេសទាក់ទងនឹងការលំបាកក្នុងការចុះឈ្មោះ បោះឆ្នោត និងការបោះឆ្នោតព្រោះការងារនេះពិបាករហូតដល់មិនអាចធ្វើបានងាយទេ ។ បញ្ហាឃោសនាអប់រំដល់មូលដ្ឋានគ្រប់រូបភាពទាំងអស់ទាំងនៅក្នុងទីក្រុង ទាំងនៅជនបទដាច់ស្រយាល គួរតែជំរុញឱ្យប្រជាជនយល់ឱ្យខ្លាំងពិសេសត្រូវចំណាយគ្រប់រូបភាពដើម្បីឱ្យប្រជាជនយល់ទាំងអត្ថន័យ ទាំងសារៈសំខាន់ក្នុងការចូលរួមបោះឆ្នោតឱ្យក្លាយទៅជាកាតព្វកិច្ចរបស់គាត់ ទាំងគណបក្សនយោបាយ ទាំងអង្គការក្នុងរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាល ។ សិទ្ធិនៃការបោះឆ្នោតអាស្រ័យលើសិទ្ធិរបស់ប្រជាពលរដ្ឋម្នាក់ៗទេកាលណាគាត់ស្រលាញ់គណបក្សនយោបាយណាគេបោះឆ្នោតឱ្យហើយ ។ ដោយឡែកអំពីការងារការពារសន្តិសុខសណ្តាប់ធ្នាប់សុវត្ថិភាពនៅក្រុងព្រះសីហនុ តាមរយៈការបោះឆ្នោតបាន ៤ លើកនេះឃើញថាមានបទពិសោធន៍ល្អ ដោយមានការចូលរួមច្រើនពីបណ្តាស្ថាប័នមានសមត្ថកិច្ចរួមមានកងរាជអាវុធហត្ថ នគរបាល យោធាជាដើម ។

លោក **ហេង សឺ** តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច ក្រុងព្រះសីហនុ បានសំដែងការគាំទ្រមតិរបស់លោកតំណាងគណបក្សសមរង្ស៊ី ដែលបានលើកឡើងថាការផ្សព្វផ្សាយមិនសូវបានទូលំទូលាយ ដោយសារការផ្សព្វផ្សាយនោះវែង ម្យ៉ាងទៀតដោយប្រជាពលរដ្ឋមិនមានការយកចិត្តទុកដាក់ ហើយថ្នាក់ភូមិក៏ដូច គជប នៅមានការខ្វះចន្លោះ និងការផ្សព្វផ្សាយតាមឡានដែលបើកលឿនពេកធ្វើឱ្យស្តាប់មិនបាន ។ លោកមានសំណូមពរទៅ គជប ថាធ្វើការផ្សព្វផ្សាយឱ្យច្បាស់លាស់ និងបញ្ជាក់ឱ្យច្បាស់លាស់ចំពោះពេល វេលាកន្លែង និងសូមឱ្យការផ្សព្វផ្សាយមានរយៈពេលវែង ដោយសហការណ៍ជាមួយមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ព្រោះយើងមិនមែនធ្វើការងារនេះដើម្បីតែគណបក្សទេ តែដើម្បីប្រទេសលទ្ធិប្រជាធិបតេយ្យ ។ លោកបានសរសើរដល់លោក **ហួត ផុន** ជាប្រធាន PEC ដែលបានបំរើការងារក្នុង PEC ក្រុងព្រះសីហនុ មិនឱ្យមានបញ្ហាអ្វីគួរឱ្យកត់សំគាល់ទេ ។ ចំនុចមួយទៀតគឺពីការិយាល័យចុះឈ្មោះបោះឆ្នោត មានការតំរង់ជួរវែងដែលធ្វើឱ្យប្រជាពលរដ្ឋពុំសូវរងចាំជាការពិត ព្រោះប្រជាពលរដ្ឋជាប់រវល់ ដូចនេះលោកមានសំណូមពរឱ្យភូមិឃុំចាត់ចាមណ្ឌលណាៗត្រូវទៅចុះថ្ងៃណាៗនាំគាត់មកវិញប្រសើរជាង ។ ការិយាល័យមួយអាចដាក់បាន ៧០០ នាក់ ហាក់ដូចជាច្រើនពេកដែលមន្ត្រីរបស់ គជប មិនអាចធ្វើបានទេ ដូចនេះគួរតែមានវិសោធនកម្មលើចំនុចនេះ ។ លោកមានសំណូមពរផងដែរថាដើម្បីកុំឱ្យមានទំនាស់ ពេលឃោសនាបោះឆ្នោត ត្រូវចាត់ទុកថាគណបក្សដែលខុសពីខ្លួនមិនមែនជាសត្រូវ ។

លោក **អាន សាម៉ុន** ចៅសង្កាត់រងទី១ សង្កាត់លេខ២ មកពីគណបក្សសម រង្ស៊ី មានសំណូមពរថារាជរដ្ឋាភិបាលគួរតែ ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋទាំងអស់ដែលមានអាយុចាប់ពី ១៨ឆ្នាំ ឡើងទៅ ឱ្យមានអត្តសញ្ញាណប័ណ្ណឱ្យបានគ្រប់ៗគ្នា ។ ទី២ នៅពេលប្រជាពលរដ្ឋអត់មានអត្តសញ្ញាណប័ណ្ណ ហើយទៅចុះឈ្មោះបោះឆ្នោតដោយសុំទំរង់ ១០១៨ ដោយមានបិទរូបថត លោកស្នើសុំថាតើអាចមានម៉ាស៊ីនរូបថតដែលថតភ្លាមបានភ្លាមដែរទេ ដើម្បីជួយសំរួលការងារផងនិងជួយសំរួលប្រជាពលរដ្ឋផង ។ បញ្ហាមួយទៀតមានប័ណ្ណបោះឆ្នោត ៩៣ ប័ណ្ណបោះឆ្នោត ៩៨ ដល់ពេលចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោតនៅឆ្នាំ ២០០២ ឬ ២០០៣ មិនត្រូវនិងការិយាល័យមុនៗ ។ ករណីខ្លះប្រជាពលរដ្ឋមានបង្កាន់ដៃថាបានចុះឈ្មោះបោះឆ្នោតរួចហើយ តែគាត់បានបាត់កន្ទុយបង្កាន់ ដៃនោះ នៅពេលគាត់ទៅរកមើលការិយាល័យមិនឃើញដោយសារមានការផ្លាស់ប្តូរពីឆ្នាំមួយទៅឆ្នាំមួយ ដូចនេះ គជប គួរតែមានប្រដាប់កិបសំរាប់កិបបង្កាន់ដៃនោះជាមួយប័ណ្ណផ្សេងឱ្យគាត់ ។ លោកមានចម្ងល់មួយទៀតទាក់ទងនឹងការបោះឆ្នោតព្រឹទ្ធសភាដែលតាមការយល់ឃើញរបស់លោកគឺថាការបោះឆ្នោតព្រឹទ្ធសភាហាក់ដូចជាអត់មានន័យ ព្រោះការបោះឆ្នោតព្រឹទ្ធសភានេះ ហាក់បីដូចជាដឹងលទ្ធផលមុន ។ លោកលើកឡើងថាកាលអាណត្តិទីពីរ គណបក្សសមរង្ស៊ីបាន ១៥ កៅអីនៅក្នុងសភា គណបក្សសមរង្ស៊ីទទួលបានកៅអីជាសភាជិកព្រឹទ្ធសភា ចំនួន ៧ អាសនៈនៅក្នុងព្រឹទ្ធសភា គឺចែកនឹងពីរ ។ គណបក្សសមរង្ស៊ីនៅក្នុងអាណត្តិទី ៣ បាន ២៤ កៅអីនៅរដ្ឋសភា បើចែកតាមអាណត្តិទីពីរនៃព្រឹទ្ធសភា គឺត្រូវបាន ១២ អាសនៈនៅក្នុងព្រឹទ្ធសភា ផ្ទុយទៅវិញបើសិនជាមើលទៅឃើញបោះឆ្នោតនេះមិនទាន់បោះទេគឺខ្ញុំវាយតម្លៃថាគណបក្សសមរង្ស៊ីនឹងទទួលបានប្រហែលជា៣កៅអីទេនៅទីក្រុងភ្នំពេញ និងនៅកំពង់ចាមមានតែប៉ុណ្ណោះ បានន័យថាហាក់បីដូចជាអាប៉ោងបើកគ្រប ។ លោកមានសំណូមពរថាបើ សិនជាធ្វើការបោះឆ្នោតព្រឹទ្ធសភាអាណត្តិក្រោយទៀត គួរតែអនុវត្តតាមការបោះឆ្នោតជាសកលទើបល្អ ។

លោក **ឱក សេរី សោភក្តិ៍** បានបញ្ជាក់ថាចំនុចដែលថាលទ្ធផលនៃការបោះឆ្នោតព្រឹទ្ធសភាអាចដឹងមុន យើងគួរតែធ្វើការតស៊ូមតិដើម្បីធ្វើឱ្យការបោះឆ្នោតព្រឹទ្ធសភានេះកាន់តែមានភាពសុក្រឹត្យឡើង ។ បើសិនគិតអំពីព្រឹទ្ធសភាដែលតែងតាំងដោយខ្លួនឯង នោះជាមិនល្អមើលឡើយដូចកាលធ្វើកន្លងទៅនេះ ។ ហើយបើសិនជាបន្តមួយអាណត្តិទៀតតាមរបៀបដូចមុននោះកាន់តែមិនល្អទៅទៀត ។ ដូច្នេះពីបោះឆ្នោតដោយខ្លួនឯងមកឱ្យក្រុមប្រឹក្សាឃុំសង្កាត់បោះឆ្នោតឱ្យមិនជាសូវល្អប៉ុន្មានទេ ព្រោះអាចដឹងមុនទៅហើយ តែល្អប្រសើរជាងបោះខ្លួនឯង ក៏ប៉ុន្តែបើសិនជាអាណត្តិក្រោយបន្តទៀតយើងត្រូវទទួលស្គាល់ទាំងអស់ពីការខ្វះខាតនៃច្បាប់នេះ ដែលត្រូវការកែប្រែដើម្បីធ្វើឱ្យយន្តការនៃការបោះឆ្នោតព្រឹទ្ធសភាកាន់តែប្រសើរឡើង ។

លោក **ទូច សន** ចៅសង្កាត់រងទី១ រាម គណបក្សហ៊្វុនស៊ិនប៉ិច បានទទួលស្គាល់ថាការចុះឈ្មោះបោះឆ្នោតនៅមានការខ្វះខាតច្រើនពិសេសឯកសារទាំងឡាយសំរាប់បង្ហាញពេលចុះឈ្មោះបោះឆ្នោត ហើយលោកបានសំណូមពរថា គជប គួរតែបើកការចុះឈ្មោះបោះឆ្នោតនេះឱ្យបានទូលាយរហូតដល់ថ្នាក់ភូមិឬឃុំ ។ ទាក់ទងនឹងការបោះឆ្នោត លោកស្នើសុំថាមិនគួរអនុញ្ញាតិឱ្យ កងកំលាំងយោធាចូលរួមបោះឆ្នោតឡើយ ដោយហេតុថាកងកំលាំងប្រដាប់អាវុធនៅមិនទាន់តម្លាភាពនៅឡើយទេបច្ចុប្បន្ន ព្រោះកងកំលាំងប្រដាប់អាវុធប្រមូលផ្តុំតាមបញ្ជាការផ្ទាល់របស់មេបញ្ជាការ និង ពេលចូលទៅបោះឆ្នោតគឺបោះឆ្នោត តាមក្រុម តាមកង មិនមែនដូចប្រជាពលរដ្ឋចេះតែបោះឆ្នោតដោយសេរីទេ ។ ចំណែកការងាររាប់សន្លឹកឆ្នោតនៅពេលបោះឆ្នោតម្តងៗលោកសង្កេត ឃើញថាមានការខ្វះខាតខ្លះត្រង់ថាពេលរាប់សន្លឹងឆ្នោត មានហិបខ្លះមិនបានយកមកច្របល់បញ្ចូលគ្នាមុនរាប់ទេ គឺថាចាក់រាប់តែម្តងដែលធ្វើឱ្យសន្លឹកឆ្នោតសំលេងទាំងប៉ុន្មាន អាចស្គាល់បានទៅតាមការកត់សំគាល់របស់អ្នកធ្វើការនៅកន្លែងនោះបានដែរ ។ ឧទាហរណ៍ លោកផ្ទាល់ឃើញថាសន្លឹកឆ្នោតបោះនៅសង្កាត់រាម សន្លឹកឆ្នោតដែលយកពីក្នុងកន្លែងយោធាបោះមក គឺមិនបានច្របល់ចូលគ្នាទេគឺរាប់តែ

សន្លឹកឆ្នោតនោះតែម្តង ម្លោះហើយការរាប់សន្លឹងឆ្នោតនៅក្នុងកន្លែងនីមួយៗនេះប្រហែលជាចង់ដឹងថាតើសន្លឹងឆ្នោតមានឥទ្ធិពលយ៉ាងម៉េចៗនោះ ។

លោក **ហួត ផុន** បានបញ្ជាក់បន្ថែមទាក់ទងនឹងការផ្សព្វផ្សាយ ដែលមានការខ្វះខាត ដោយសារថាប្រជាពលរដ្ឋនៅតំបន់ដាច់ស្រយាល តែ PECនឹងចលនាទៅតាមរដ្ឋអំណាច គណបក្សនយោបាយ ព្រោះគណបក្សនយោបាយទោះដាច់ស្រយាលយ៉ាងណាក៏ដោយក៏មានភាគីគណបក្សនយោបាយនៅទីនោះដែរ ហើយ PEC នឹងទទួលយកវិធីសាស្រ្តនេះសំរាប់អនុវត្តនៅពេលខាងមុខ ។ ចំពោះវិធានការពិគ្រោះពិភាក្សាប្រចាំសប្តាហ៏ PEC បានផ្សព្វផ្សាយទៅគណបក្សនយោបាយអស់ហើយថា PEC ផ្សព្វផ្សាយតាមវិទ្យុទូរទស្សន៏ ជារឿងកំប្លែងនៅតាមទីប្រជុំជនមួយចំនួនដែលមានសំលេងវិទ្យុទូរទស្សន៏ ។ ចំពោះតំបន់ដាច់ស្រយាល ក៏មានរដ្ឋអំណាចគណបក្សចូលរួមដែរហើយបើមិនបានគ្រប់គ្រាន់ទេគឺសូមអធ្យាស្រ័យទុកជាបទពិសោធន៏ទៀត ដើម្បីពេលបោះឆ្នោតក្រោយ ។ ចំពោះការផ្លាស់ប្តូរការិយាល័យតាមនីតិវិធីគឺ PEC បានទំនាក់ទំនងចៅសង្កាត់ ព្រោះឥឡូវនេះចៅសង្កាត់មានតួនាទីជាអ្នកចុះឈ្មោះបោះឆ្នោត ដើម្បីសុំការបញ្ជាឯកភាពក្នុងការផ្លាស់ប្តូរការិយាល័យនេះ ។ ហើយការផ្លាស់ប្តូរក៏មិនឱ្យឆ្ងាយពីគ្នារហូតដល់រកមិនឃើញទេ ។ ឧទាហរណ៏ថាឆ្នាំ ១៩៩៨ ឬក៏២០០២ PEC បានយកដីឡូតិ៍ធ្វើជាការិយាល័យ ឥឡូវមានសាងសង់ផ្ទះនៅលើដីនោះធ្វើឱ្យ PEC មិនអាចដាក់ការិយាល័យបោះឆ្នោតនៅលើដីនោះទៀតទេ ហើយនៅទីក្រុងពិបាករកទីកន្លែងសមរម្យសំរាប់ការិយាល័យ បោះឆ្នោតបានទេ ។ PEC បានព្យាយាមណាស់ កាន់តែព្រួយបារម្ភណ៏ណាស់ទាក់ទងនឹងបញ្ហានេះ ។ ការផ្លាស់ប្តូរនេះត្រូវតែផ្សព្វផ្សាយទូលាយឱ្យបងប្អូនដែលនៅការិយាល័យនេះដឹងថាមានការផ្លាស់ប្តូរទៅកន្លែងផ្សេង ប៉ុន្តែលទ្ធភាពនៃការផ្សព្វផ្សាយនៅមានកំរិត ។ ចំនុចលោកខាងគណបក្សសមរង្ស៊ីលើកឡើងថា ចំនួន ៧០០ នាក់សំរាប់ការិយាល័យមួយច្រើន ហើយសុំឱ្យពន្យាម៉ោង PEC នឹងទទួលយកសំណូមពរនេះហើយ សូមបញ្ជូនសំណូមពរនេះតាមរយៈខប់សែលដើម្បីរាយការណ៏ជូនអង្គប្រជុំនៅថ្នាក់ជាតិសុំកែសម្រួល ព្រោះចំនួន ៧០០នាក់នៅការិយាល័យតែ១ បើកាលណាមានមួយយឺតគឺធ្វើឱ្យស្ទះនិងមិនមានពេលគ្រប់គ្រាន់ទេ ។

ទាក់ទងនឹងការផ្សព្វផ្សាយតាមរថយន្ត លោកក៏បានកត់សំគាល់ឃើញថា ធម្មតាកាសែតរឿងខ្លីមួយ ត្រូវតែចាក់ផ្សាយត្រង់ចំនុចណាឱ្យប្រជាពលរដ្ឋយល់ពីសាច់រឿងពីដំបូងរហូតដល់ចប់ ដែលនេះជាបញ្ហាខ្វះចន្លោះរបស់ PEC នៅក្នុងការផ្សព្វផ្សាយ ហើយលោកសន្យាថានឹងធ្វើការកែតម្រូវនៅថ្ងៃក្រោយ ។ ចំពោះប្រជាពលរដ្ឋខ្មែរដែលគ្មានអត្តសញ្ញាណ នៅក្នុងការងារចុះឈ្មោះនេះ គឺជាការព្រួយបារម្ភណ៏ដ៏ធំធេងបំផុត ហើយរាជរដ្ឋាភិបាលក៏ខិតខំធ្វើអត្តសញ្ញាណប័ណ្ណ ធ្វើបញ្ជីជាតិកំណើត ហើយ PECក៏មានការចុះឈ្មោះប្រចាំឆ្នាំឆ្នាំសំរាប់ក្មេងគ្រប់អាយុដល់ពេលត្រូវចុះឈ្មោះបោះឆ្នោតបានជាងបីពាន់នាក់ ។ ការលំបាកនៅត្រង់ថាប្រជាពលរដ្ឋភាគច្រើនមិនមានប័ណ្ណ ឬឯកសារណាមួយដែលសំគាល់ថាឆ្នាំកំណើតនៅពេលដែលមកចុះឈ្មោះនោះទេ ។ លុះត្រូវបំពេញទំរង់ ១០១៨ ដោយមានបិទរូបថតដែលអាចមានតម្លៃពី ១ពាន់ទៅ ២ពាន់រៀល ។ តំលៃនេះនៅស្រុកស្រែខ្ពស់ សំរាប់ប្រជាពលរដ្ឋជាកសិករ ហើយនេះការលំបាករបស់ប្រជាពលរដ្ឋ ។ ចំណែកវិធីដោះស្រាយគួរតែមានការចូលរួមទាំងអស់គ្នា ទាំងគណបក្សនយោបាយ ទាំងរដ្ឋអំណាចគ្រប់ជាន់ថ្នាក់ និងយើងទាំងអស់គ្នាផង ព្រោះការបោះឆ្នោតមិនមែនប្រព្រឹត្តទៅតែម្នាក់ឯងទេ ។ PEC គ្រាន់តែជាចុងភៅមួយទេធ្វើម្ហូបឆ្ងាញ់ សាបឬប្រៃ បើថាសាបសូមជួយថែមអំបិលបន្តិចទៅ ។ បញ្ហាលោក **សន** បានបញ្ជាក់ថាការចាក់ហិបសន្លឹកឆ្នោត មិនមកច្របូកច្របល់ជាការខុសច្បាប់ទាំងស្រុង ខុសនីតិវិធីទាំងស្រុង ពេលនោះបើគណបក្សនយោបាយរាយការណ៏ មក PEC នឹងចុះត្រួតពិនិត្យអង្កេតភ្លាម ។ លោកមិនដែលជំរាបទៅ CEC ប្រចាំឃុំរាមឱ្យធ្វើដូច្នេះទេ ហើយទើបតែថ្ងៃនេះទេដែលលោកបានដឹង ។ លោកសូមប្រកាសក្នុងអង្គប្រជុំធ្វើរបៀបនេះគឺខុស ហើយទទួលស្គាល់ថានេះជាការខ្វះចន្លោះរបស់ PEC ។

លោក **ឱក សេរី សោភ័ក្តិ** បានលើកឡើងថា សំណូមពរសុំឱ្យបន្ថែមម៉ោង នៅពេលការិយាល័យបោះឆ្នោតមានអ្នកបោះឆ្នោតច្រើន ហាក់ដូចជាមិនអាចធ្វើបានទេ ព្រោះច្បាប់មិនអាចបង្កើតឡើងសំរាប់តែកន្លែងមួយនោះទេ ច្បាប់តោងតែមានវិសាលភាពពេញទាំងព្រះរាជាណាចក្រកម្ពុជា ។ តាមការសង្កេតឃើញថាប្រជាពលរដ្ឋមកបោះឆ្នោតច្រើន ប្រហែលពីរម៉ោងដំបូងប៉ុណ្ណោះ ចាប់ពីម៉ោង ១១ទៅ ពុំសូវមានអ្នកបោះឆ្នោតច្រើនឡើយ ។ កាលណាមានបន្ថែមម៉ោងធ្វើឱ្យការរាប់សន្លឹកឆ្នោតកាន់តែយប់ជ្រៅដែលនាំឱ្យមានការលំបាកកាន់តែខ្លាំង ។ ក៏ប៉ុន្តែបើសិនជាមានករណីពិសេសបែបនេះ គជបអាចបន្ថែមការិយាល័យបោះឆ្នោតមួយទៀត ហើយបើធ្វើតាមវិធីនេះ ច្បាប់អនុញ្ញាតិឱ្យបាន ។ កន្លែងណាដែលខ្វះកំលាំងយើងអាចយកនិស្សិតស្ម័គ្រចិត្តឱ្យជួយចុះឈ្មោះបោះឆ្នោតដោយផ្តល់ឱ្យតែបាយទឹក និង កន្លែងស្នាក់នៅប៉ុណ្ណោះ ។

## ៣. មតិរបស់អ្នកចូលរួមបន្ទាញពីការប្រឈមនានាឡាយនៅក្នុងយន្តការរៀបចំការបោះឆ្នោតក្នុងបរិបទក្រុងព្រះសីហនុ

លោក **សុខ សារ៉ាត** ប្រធានគណបក្ស សម រង្ស៊ី ស្តីទីក្រុងព្រះសីហនុ បានលើកឡើងថា មួយរយៈកន្លងមកការជ្រើសរើសប្រធាន CEC និងបុគ្គលិក CEC នៅតាមមូលដ្ឋាននេះមិនទាន់មានតម្លាភាព ដែលអាចឱ្យគណបក្សនយោបាយអាចប្រកួតប្រជែងអស់ចិត្តនៅឡើយទេព្រោះ PEC រើសបុគ្គលិកច្រើនតែប្រកាន់បក្សពួកសូម្បីតែការជ្រើសរើសបុគ្គលិក CEC ក៏ដូច្នេះដែរ ។ លោកមានសំណូមពរថាសូមឱ្យការជ្រើសរើសប្រធាន CEC និង បុគ្គលិក CEC លើកក្រោយសូមឱ្យមានតម្លាភាព ដោយមិនប្រកាន់បក្សពួក ។ ទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ទាំងលោកប្រធានលេខាធិការដ្ឋាន ទាំងគណបក្សនយោបាយសុទ្ធតែទទួលស្គាល់ថា មានការលំបាកព្រោះមានទាមទាអត្តសញ្ញាណ មានឯកសារគ្រប់គ្រាន់ ទើបអាចចុះឈ្មោះបាន ហើយប្រជាពលរដ្ឋមិនមានឯកសារទាំងនេះឡើយ។ លោកស្នើថាគួរតែមានិវសោធនកម្មច្បាប់ដោយគ្រាន់តែបញ្ជាក់ថាឱ្យតែខ្មែរសក់ខ្មៅរួញអង្គាជី និយាយខ្មែរច្បាស់ ទៅចុះឈ្មោះបោះឆ្នោតបានហើយមិនចាំបាច់មានឯកសារគ្រប់គ្រាន់សំរាប់ទៅបញ្ជាក់ទេ តែផ្ទុយទៅវិញជួនកាលអ្នកខ្លះនិយាយភាសាខ្មែរមិនច្បាស់ផង ឈ្មោះមិនមែនជាឈ្មោះខ្មែរទៀត ទើបតំរូវឱ្យមានឯកសារគ្រាប់គ្រាន់ ប៉ុន្តែបុគ្គលនោះមានសិទ្ធិស្របច្បាប់ទៅបោះឆ្នោត កាលណាមានអត្តសញ្ញាណប័ណ្ណ ។ លោកលើកឡើងថាសំណូមពរដែលសុំឱ្យមានអត្តសញ្ញាណប័ណ្ណគ្រប់គ្នា ប្រហែលមិនអាចធ្វើទៅរួចទេ ព្រោះជួនកាលគាត់ជាពិសេសយុវសិស្ស អាយុលើសពី ១៨ ឆ្នាំ ប៉ុន្តែមិនមានពេលណាមកធ្វើអត្តសញ្ញាណប័ណ្ណ ។ ដូចនេះយុវសិស្សរាប់ពាន់រាប់ម៉ឺននាក់ក្នុងមួយឆ្នាំៗ ខកខានមិនបានបោះឆ្នោតទេ ដោយសារគាត់មិនមានឯកសារគ្រប់គ្រាន់ ។ ទាក់ទងនឹងច្បាប់បោះឆ្នោតពិសេសរូបមន្តបែងចែកកៅអីនៅរដ្ឋសភា បើខាងណាធំបានកៅអី តែបើខាងតិចអត់មានសោះ ។ ជាក់ស្តែងដូចជានៅក្រុងព្រះសីហនុសំឡេងគាំទ្រគណបក្សសម រង្ស៊ីមាន ១៨៥០០ នាក់ ដែលជាចំនួនច្រើន ប៉ុន្តែចំនួននេះមិនមានប្រយោជន៏ ព្រោះក្រុងព្រះសីហនុ មានតែមួយកៅអី ។ **លោកសួរថាតើច្បាប់បោះឆ្នោតអាចកែសំរួលតាម ច្បាប់សម័យអ៊ុនតាក់ទេ ?** កាលសម័យនោះ ច្បាប់បានកំណត់ថា កាលណាមានសល់កន្ទុយ យកទៅបូកចូលនៅកន្លែងមួយទៀត ព្រោះសំលេងគាំទ្រដែលគាត់ខំទៅបោះឆ្នោត ។ បើមកបោះឆ្នោតសំរាប់តែមួយកៅអីបែបនេះ អត់មានដណ្តើមលេខ ២ ទេ ហើយធ្វើបែបនេះអាចឱ្យមនុស្សធុញក្នុងការមកបោះឆ្នោតលើកក្រោយៗទៀត ។

លោកបានឯកភាពជាមួយលោកតំណាងគណបក្ស ហ្វ៊ុនស៊ិនប៉ិច ដែលលើកឡើងថានៅរាមកងកំលាំងប្រដាប់អាវុធ មិនបាច់

មានការបោះឆ្នោតទេ ព្រោះកងកំលាំងប្រដាប់អាវុធជាអង្គភាពមួយ ទទួលបញ្ជាពីមនុស្សម្នាក់ ដូច្នោះត្រូវតែធ្វើតាមមនុស្សម្នាក់ ហើយម្យ៉ាងទៀតក្នុងនាមជាមនុស្សអព្យាក្រឹត្យទៀតផង ។ និយាយនេះមិនមែនបានន័យថាបិទសិទ្ធិទេ ព្រោះរដ្ឋធម្មនុញ្ញចែងថាឱ្យតែប្រជាពលរដ្ឋមានអាយុចាប់ពី ១៨ ឡើងទៅមានសិទ្ធិបោះឆ្នោតទាំងអស់គ្នា ប៉ុន្តែមិនបានចែងថាមានអ្នកអព្យាក្រឹត្យ ឬក៏អ្នកមិនអព្យាក្រឹត្យទេ ។ បញ្ហាមួយទៀតត្រង់ថាពេលចុះឈ្មោះបោះឆ្នោតមានកន្ទុយប័ណ្ណ តែគាត់មិនរក្សាទុកឱ្យល្អទេ ជួនកាលទុកភ្លេចនៅក្រោមពូក កណ្តុរស៊ី ឬបាត់ក៏មាន ហើយលោកសំណូមពរទៅ គជប សូមឱ្យមានថវិការគ្រប់គ្រាន់សំរាប់ធ្វើប័ណ្ណបោះឆ្នោតដូចបណ្ណ័បោះឆ្នោត ៩៨ ឬក៏អ៊ុនតាក់ព្រោះអាចទុកបានយូរ ។ បញ្ហាមួយទៀតនៅត្រង់ថាច្បាប់កំណត់ថាបើគ្មានអត្តសញ្ញាណប័ណ្ណ ទាល់តែមានអ្នកបញ្ជាក់ពីទីលំនៅទៀត ហើយមានរកមនុស្ស ២-៣ នាក់មកបញ្ជាក់ទៀត ដែលនេះបង្កការលំបាកដល់អ្នកមកពីឆ្ងាយ ។ ឧទាហរណ៍ដូចថាមានប្អូនៗខ្លះធ្វើការជាបុគ្គលិកសណ្ឋាគារ មកពីស្រុកឆ្ងាយមិននៅក្រុងព្រះសីហនុ គាត់នៅកំពង់ចាម ដូច្នោះបើគាត់ចង់ទៅបោះឆ្នោតនៅខេត្តកំពង់ចាម គាត់ត្រូវចំណាយពេលវេលា ៣ថ្ងៃឈប់ មួយថ្ងៃ ថ្ងៃបោះឆ្នោតមួយថ្ងៃ ថ្ងៃត្រឡប់មកវិញមួយថ្ងៃ ហើយសាហ៊ុយគាត់ត្រូវចាយពី ២០ដុល្លា ទៅ ៣០ ដុល្លា ដែលនេះអាចមានការបោះបង់ចោលមិនមកបោះឆ្នោតឡើយព្រោះធ្វើឱ្យគាត់ខាតប្រយោជន៍ ដូច្នោះលោកមានសំណូមពរថាសុំឱ្យធ្វើវិសោធនកម្មច្បាប់បោះឆ្នាតនៅចំនុចខ្លះ។ លោកបានសសើរដោយស្មោះចំពោះបញ្ហាសន្តិសុខនៅទីក្រុងព្រះសីហនុ ដែលកងកំលាំងប៉ូលីស អាវុធហត្ថ យោធា បានបង្ករមិនឱ្យមានភាពតានតឹងណាមួយឡើយ និងមិនមានអំពើហិង្សា រហូតសំលាប់គ្នានោះទេ ។ មានខ្លះតាមរយៈការគំរាមគំហែងតាមផ្លូវចិត្ត ឬសំភារៈ នៅតាមមូលដ្ឋានច្រើនករណី ដែរមិនជាបញ្ហាធ្ងន់ធ្ងរឡើយ ។

លោក **ឱក សេរី សោភក្តិ៍** បានបញ្ជាក់ជូនអង្គប្រជុំជ្រាបថា គោលបំណងធំរបស់យន្តការខប់សែលគឺកសាងនូវវប្បធម៌នៃការពិភាក្សាគ្នាដើម្បីឈានទៅរកដំណោះស្រាយដោយសន្តិវិធី ហើយចំពោះរាល់ខ្លឹមសារទាំងឡាយនៃកិច្ចពិភាក្សា និងការសំរេចចិត្តលើចំនុចនីមួយៗអាស្រ័យលើអ្នកចូលរួមទេ ខប់សែលគ្រាន់តែដើរតួរជាអ្នកសំរបសំរួលប៉ណ្ណោះ ។

លោក **ជ័យ វិស៊ុន** អភិបាលរង ខ័ណ្ឌស្ទឹងហាវ បានសង្កេតឃើញថាការផ្សព្វផ្សាយក្នុងពេលបោះឆ្នោតម្តងៗកាន់តែមានការរីកចំរើនច្រើន មានភាពទូលំទូលាយ និងមានច្រើនរូបភាពរួមមានតាំងពី ផ្ទាំងរូបភាពធំ វិទ្យុ មេក្រូ ពិសេសយើងអាចឆ្លុះបញ្ចាំងតាមរយៈលទ្ធផលនៃអ្នកបោះឆ្នោតកន្លងមកដែលកើនឡើងជាបណ្តើពី ៨០ ទៅ ៩០ ភាគរយ ដែលចំនុច នេះអាចបញ្ជាក់យ៉ាងច្បាស់ថាការផ្សព្វផ្សាយនេះមានភាពទូលំទូលាយណាស់ ។ ទន្ទឹមនិងនេះដែរលោកក៏ស្នើឱ្យការផ្សព្វផ្សាយនេះបានទូលំទូលាយបន្ថែមទៀត តាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយ ។ ទាក់ទងនឹងការឃោសនាមានលក្ខណៈទូលំទូលាយដោយសារមានក្រមសីលធម៌ មានច្បាប់ត្រឹមត្រូវដោយមានការគោរពគ្នាល្អជាបណ្តើរៗពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយ ។ ចំពោះការបោះឆ្នោតព្រឹទ្ធសភា លោកមានសំណួរថាតើយើងអនុវត្តន៏តាមច្បាប់នៃប្រទេសណាដែរដែលយកតាមរបៀបអសកលបែបនេះ ហើយហាក់ដូចជាដឹងលទ្ធផលមុនទាំងអស់ ។ ការរាប់សន្លឹកឆ្នោតគួរតែរាប់នៅកន្លែងដែលបោះឆ្នោតតែម្តងដើម្បីឱ្យប្រជាជនអាចមើលឃើញដែរ និងដើម្បីបំបាត់ការសង្ស័យផង ។

លោក **សិរិទ្ធ ភុំ** តំណាងគណបក្សប្រជាជនក្រុងព្រះសីហនុ បានលើកឡើងថាទំនាស់នៅពេលបោះឆ្នោតកន្លងមកតែងតែមានប៉ុន្តែសុទ្ធតែអាចសំរបសំរួលដោះស្រាយបាបជាបន្តបន្ទាប់ មិនឱ្យមានប៉ះពាល់ទៅដល់ឥទ្ធិពលនៃការបោះឆ្នោតទេ ។ ពាក់ពន្ធ័នឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត ច្បាប់បោះឆ្នោតបច្ចុប្បន្នក្រោយពីបានធ្វើវិសោធនកម្ម ធ្វើប្រតិភូកម្មអំណាចឱ្យទៅចៅសង្កាត់មានសិទ្ធិចុះឈ្មោះបោះឆ្នោត ហើយបើពិនិត្យច្បាប់បោះឆ្នោតនេះគឺទូលំទូលាយសំរាប់ការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត តែការលើកឡើងរបស់វាគ្មិនកន្លងមកហាក់ដូចជាតឹង ។ ក្នុងនាមគណបក្សប្រជាជនកម្ពុជាក្រុងព្រះសីហនុ

ដែលបានចុះជាប់ជាមួយលេខាធិការដ្ឋានពាក់ពន្ធ័និងការប្រជុំដោះស្រាយរាល់បញ្ហានិងក្នុងការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះនេះ គឺអ្នកដែលត្រូវធ្វើសកម្មភាពមិនមែនតែចៅសង្កាត់ទេគឺបានផ្តល់អាទិភាពទៅឱ្យគណបក្សនយោបាយទាំងអស់ ដែលឈរជើងនៅក្រុងព្រះសីហនុ ធ្វើសកម្មភាពតាមបណ្តាញរបស់ខ្លួន ហើយក៏មិនមែនជាតួនាទីរបស់លោកប្រធានលេខាធិការដ្ឋានតែមួយរូបដែរ កន្លងមកគឺជាការទទួលខុសត្រូវរួម ជាពិសេសគឺសាម៉ីគណបក្សនេះឯងដែលជាអ្នកទទួលខុសត្រូវណែនាំអប់រំកំលាំងរបស់ខ្លួន ឱ្យទៅពិនិត្យបញ្ជីឈ្មោះ ឱ្យទៅចុះឈ្មោះទៅតាមរយៈកំលាំងរបស់ខ្លួនហ្នឹង ។ លោកសូមសរសើរដោយស្មោះចំពោះលោកប្រធាន លេខាធិការដ្ឋានគឺថារាល់បញ្ហាអ្វីដែលកើតឡើងមិនចាំបាច់រឿងធំទេ លោកប្រធានតែងតែបានហៅតំណាងគណបក្សទាំងអស់មកពិភាក្សាគ្នា ឯកភាពគ្នាជាគោលការណ៍យកទៅអនុវត្តន៍ រវៀង៧ខ្លួននេះជាចំនុចល្អ ហើយមិនមានបញ្ហាអីដែលថាត្រូវតឹងទេ ។ ចំនុចដែលថាចុះឈ្មោះមិនបាន ១០០ ភាគរយគឺវាអាស្រ័យទៅលើគោលជំហររបស់ការភ្ញាក់រលឹក និងមិនយល់ពីកាតព្វកិច្ចរបស់ខ្លួនដែលជាប្រជាពលរដ្ឋ ។ ឥឡូវនេះចំនុចខ្សោយរបស់យើងនៅត្រង់ប្រជាពលរដ្ឋខ្វះឆន្ទៈ ទោះបីទៅចលនាឃោសនាអប់រំតាមរយៈគណបក្សក្តី ការអប់រំតាមរយៈលេខាធិការដ្ឋាន រៀបចំការបោះឆ្នោតក្តី ក៏ប៉ុន្តែការយកចិត្តទុកដាក់របស់ខ្លួនជាពលរដ្ឋដើម្បីចូលទៅពិនិត្យបញ្ជីឈ្មោះដើម្បីចូលទៅចុះឈ្មោះគឺថានៅតិច ។ យើងត្រូវទទួលស្គាល់ថាក៏រិតនៃការភ្ញាក់រលឹករបស់ប្រជាពលរដ្ឋឥឡូវហាក់ដូចជាស្ពប់ស្ពល់និងការបោះឆ្នោត ទោះអញ្ជើញគាត់ឱ្យទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោត គាត់មិនទៅ អញ្ជើញគាត់ឱ្យទៅចុះឈ្មោះបោះឆ្នោតគាត់មិនទៅ តើនេះកំហុសធ្លាក់ទៅលើអ្នកណា? លទ្ធផលបោះឆ្នោតដូចបានលើកឡើងថា ៨០ ភាគរយ ក៏ប៉ុន្តែបំណងរបស់ គជប បំណងរបស់ប្រធានលេខាធិការដ្ឋានចង់ឱ្យបាន ១០០ ភាគរយ មិនចង់ឱ្យពលរដ្ឋណាមិនទៅចុះឈ្មោះ ។ លោកក៏សរសើរចំពោះសកម្មភាពនិងលទ្ធផលរបស់ PEC និងមន្ត្រីគ្រប់ថ្នាក់ដែលទទួលការដឹកនាំនៅគ្រប់សង្កាត់គឺថាបានយកចិត្តទុកដាក់លើការងារនេះរហូតទទួលបានលទ្ធផលល្អ ។ ដោយឡែកសំរាប់ឆ្នាំ ២០០៥ នេះ ហាក់ដូចជាមានការធ្លាក់ចុះសំរាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះ ។ ដូចនេះជាសំណូមពរនៅក្នុងចំនុចខាងលើនេះគ្រប់គណបក្សនយោបាយទាំងអស់ គួរតែពង្រឹងកំលាំងរបស់ខ្លួន ជំរុញឱ្យចូលរួមគ្រប់សកម្មភាពនៃការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះនេះកុំចាំតែលើលោកប្រធានលេខាធិការដ្ឋានតែម្នាក់គាត់ ហើយការងារនេះច្បាប់មិនឃាត់ឃាំងទេ ។

ពាក់ព័ន្ធនិងការឃោសនាលោកពិនិត្យឃើញថាច្បាប់នីតិវិធីនៃការឃោសនាទាំងអស់គ្រប់ការបោះឆ្នោត មានការបោះឆ្នោតខ្លះ រយៈពេលឃោសនាមាន ២០ ថ្ងៃ ការបោះឆ្នោតខ្លះមានរយៈពេលនៃការឃោសនា ៣០ ថ្ងៃ ហើយបូកនឹងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើគ្រប់សកម្មភាពសំដៅបំរើឱ្យការឃោសនានេះ និងការឃោសនារបស់ PEC ក្រុង ទាំងអស់នេះអាចនិយាយបានថាមានសភាពផុសផុលណាស់ មិនមានអីថាការឃោសនាមិនបានជ្រួតជ្រាបទៅដល់ផ្ទះប្រជាជន ។

ពាក់ពន្ធ័នឹងការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោតបើតាមលោកធ្លាប់ចូលរួមនិងសង្កេតគឺថាគ្រប់គណបក្សនយោបាយទាំងអស់សុទ្ធតែមានភ្នាក់ងាររបស់ខ្លួន មិនឱ្យខ្វះការិយាល័យបោះឆ្នោតណាមួយទេ ហើយសុទ្ធតែប្រយ័ត្នណាស់ពេលបំពេញតួនាទីភារៈកិច្ចរបស់ខ្លួន មិនឱ្យមានបន្លំឡើយ ។ លោកមានសំណូមពរថាសូមឱ្យ តំណាងគណបក្សពិនិត្យឡើងវិញពីនីតិវិធីរាប់សន្លឹកឆ្នោតរបស់ PEC គឺហាក់ដូចជាពុំមានការខ្វះចន្លោះណានោះឡើយ ។ លោកមានសំណូមពរថាដើម្បីសំរួលដោះស្រាយបញ្ហា ត្រូវតែរកឬសគល់នៃបញ្ហា ហើយឬសគល់បញ្ហានៅត្រង់ថាប្រជាជនមិនសូវយល់ច្បាស់ នៅពេលប្រជាជនមិនសូវយល់ ក៏មិនមានការចូលរួម ។ ដំណោះស្រាយគឺមានតែរួមគ្នាអប់រំឱ្យបានជ្រាបទៅដល់ប្រជាពលរដ្ឋទាំង១៣-១៤ ម៉ឺននាក់នៅ ក្រុងនេះ ទាំង គជប ទាំង PEC ទាំងគណបក្សនយោបាយដើម្បីឱ្យប្រជាពលរដ្ឋយល់អំពីកាតព្វកិច្ចរបស់ខ្លួននៅក្នុងការចូលរួមការបោះឆ្នោតនេះ ។ ទាក់ទងនឹងកាលបរិច្ឆេទនៃការបោះឆ្នោតលោកមានយោបល់ថា យើងបានចាត់ទុកថាប្រទេសកម្ពុជាជាប្រទេសកសិកម្មដែលមានកសិករ ៨៥ ភាគរយ

ហើយបើយើងពិនិត្យ ទៅលើខែ ៧ គឺជារដូវបង្កបង្កើនផលដែលប្រជាពលរដ្ឋជាប់រវល់ច្រើន ត្រូវទៅស្ទូង ដែលធ្វើឱ្យគាត់អាចមិនទៅបោះឆ្នោត តែដោយឡែកខាងក្រុងព្រះសីហនុនៅខែ៧ ខែ៨ ជារដូវភ្លៀងច្រើនដែលនេះអាចប៉ះពាល់ដល់អ្នកចូលរួមបោះឆ្នោតដែល ។ ដូចនេះជាសំណូមពរតាមរយៈសិក្ខាសាលានេះទៅ គណកម្មាការជាតិរដ្ឋសភា និង ព្រឹទ្ធសភា គួរតែបញ្ជាក់អំពីហេតុផលថាតើអាចធ្វើវិសោធនកម្មត្រង់ប្រការនេះ មាត្រានេះបានដែរទេ?

លោក**អន សុខ** ចៅសង្កាត់រងទី១ សង្កាត់វាលរេញ ខ័ណ្ឌព្រៃណប់ ក្រុងព្រះសីហនុ ខាងគណបក្ស សមរង្ស៊ី មានសំណូមពរពីរ សំណូមពរទី១ បើប្រជាជនមិនចេះអក្សរក្រោយពីពេលខិតប័ណ្ណដែលបាចតាមឡាន គាត់ទទួលបានតែមិនចេះមើលសោះ តើខិតប័ណ្ណនោះក្លាយទៅជាមិនសូវមានប្រសិទ្ធិភាព ។ សំណូមពរទី ២ នៅពេលដែលមានប្រជាពលរដ្ឋមិនចេះអក្សរទៅបោះឆ្នោត អ្នកយាមការិយាល័យ ប្រាប់ថាអត់ឃើញឈ្មោះនៅការិយាល័យនេះ ក៏ ជំរាបគាត់ឱ្យទៅមើលនៅការិយាល័យមួយផ្សេងទៀត ។ នៅពេលដែលគាត់ទៅដល់ការិយាល័យមួយទៀតអ្នកយាមថាមិនឃើញទៀត រុញទៅនេះ រុញទៅនោះ ៣-៤កន្លែង គាត់ឈប់បោះឆ្នោត ។ បញ្ហាមួយទៀតអ្នកខ្លះដែលមានពណ៌សម្បុរដូចមិនមែនជាខ្មែរ តែមានឯកសារគ្រប់គ្រាន់ទាំងអស់ ហើយមានសិទ្ធិបោះឆ្នោត តែចំពោះខ្មែរដែលមានសាច់ឈាមថាគួរជាខ្មែរ បែរជាអត់មានសិទ្ធិបោះឆ្នោតក៏មាន ។ មួយទៀតមានអ្នកធ្វើការនៅក្នុងរោងចក្រ កាលចុះឈ្មោះបោះឆ្នោតគាត់បានធ្វើនៅស្រុកឆ្ងាយ ។ នៅពេលជិតផុតអាណត្តិចុះឈ្មោះបោះឆ្នោត គាត់រត់ទៅធ្វើនៅសង្កាត់ គាត់ថាសូមជួយចុះឈ្មោះបោះឆ្នោតផង បើមិនបានជួយទេ គាត់មិនបានបោះឆ្នោត តើចំនុចនេះគួរដោះស្រាយដោយវិធីណា? លោកបានលើកឡើងចំនុចមួយជំរាបថាប្រជាពលរដ្ឋខ្មែរ ហាក់ដូចជាមានចំនុចមួយដែលខ្លាច ឃ្លាន និងខ្លៅ ដែលធ្វើឱ្យមានការលំបាកក្នុងការដោះស្រាយរាល់បញ្ហាដែលប្រជាពលរដ្ឋមាន ។

លោក **ហួត ផុន** ចំពោះបញ្ហាលោកអភិបាលរងស៊ឹងហាវ បានបញ្ជាក់ច្បាស់លាស់ជាច្រើនអន្លើអំពីសកម្មភាពកន្លងមកនៃការបោះឆ្នោតហើយក្នុងនោះក៏មានមោទនភាពគ្រប់ស្ថាប័នរដ្ឋក៏ដូចជាស្ថាប័នបោះឆ្នោតនិងគ្រប់គណបក្សនយោបាយ ដែលហាក់ដូចជាថារៀបរយត្រឹមត្រូវបើខ្វះខាតដោយចំនុចណាមួយនោះក៏បញ្ហាមិនធ្ងន់ធ្ងរ ដែលថាឱ្យបានត្រឹមត្រូវ មិនអាចថាត្រឹមត្រូវតែតខ្វោះ ១០០ ភាគរយទេ ។ ទី ២ លោកប្រធានស្ដីទីគណបក្សសមរង្ស៊ីមានប្រសាសន៍ថាការជ្រើសរើសមិនយុត្តិធម៌ គឺក្នុងនាមជា PEC ក្រុងព្រះសីហនុ សូមបញ្ជាក់ថាការលើកឡើងនេះអាចជាស្មារតីមួយរលឹក PEC ទេ ត្រង់ថាលោកផ្ទាល់ លោកមិនមានភាពលំអៀងទេ ព្រោះមុននិងធ្វើការនៅ PEC នេះគឺសុទ្ធតែមានការណែនាំពីថ្នាក់ដឹកនាំជាន់ខ្ពស់ ហើយកាលណាមានលំអៀង មានបញ្ហាខុសឆ្គងលើប្រការណាមួយ លោកនឹងត្រូវជាប់ទោស ផាកពិន័យជាប្រាក់ ៥០ លានក្នុងច្បាប់ហើយមានទោស ។ ប៉ុន្តែការខ្វះខាតដោយអន្លើណាមួយនោះ PEC អាចពិចារណាឡើងវិញ ។ ជួនការការដោះស្រាយនេះមិនមែនជាភាពទល់ច្រកទេ ការដោះស្រាយនេះដើម្បីឆ្លុះបញ្ចាំងអំពីធាតុពិតនៃការចោទប្រកាន់ និងមិនពិតនៃការចោទប្រកាន់ ឧទាហរណ៍មានពាក្យបណ្ដឹងមួយនេះ លោកមិនបានដោះស្រាយទេ ។ លោកតែងតែចាត់តាំងមន្ត្រីសេវាច្បាប់ទៅអង្កេតជាមួយអង្គការក្រៅរដ្ឋាភិបាលជាមួយអ្នកដើមបណ្ដឹង និង មន្ត្រីឃុំសង្កាត់ដែលនៅទីតាំងនោះ រួចពិចារណាថាតើពាក្យបណ្ដឹងនេះត្រឹមត្រូវឬទេ ហើយឱ្យធ្វើកំណត់ហេតុឡើងមកជួបជុំគ្នា ហើយបើមិនត្រូវទេ PEC អាចបដិសេធនពាក្យបណ្ដឹង ព្រោះពាក្យបណ្ដឹងគ្មានមូលដ្ឋានច្បាស់លាស់ មិនមែនថាភ្លាម១ទេ ។ ចំនុចដែលតំណាងគណបក្សប្រជាជនកម្ពុជាបានលើកពីគុណសម្បត្តិនៃ PEC ក្រុង គឺ PEC តែងតែចូលរួមសហការណ៍ជាមួយរដ្ឋអំណាចគ្រប់ជាន់ថ្នាក់ មានតាំងពីថ្នាក់អភិបាលក្រុង អភិបាលខ័ណ្ឌ មន្ត្រីរាជការដែលជាកងប្រដាប់អាវុធ និងគ្រប់គណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្រៅរដ្ឋាភិបាល តែលោកមិនបានលើកអំពីគុណសម្បត្តិទេ លោកលើកតែចំនុចខ្វះខាតដូចដែលបានលើកជូនអង្គប្រជុំរួចស្រេចហើយ ។ បើមានសំណូមថាសុំផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹង គឺ PEC ក៏សូមអបអរសាទរដែលថានិងបង្កើនការផ្សព្វផ្សាយទូលំទូលាយតទៅទៀត បង្កើន

ការជួបជុំមន្ត្រីរាជការ គ្រប់គណបក្សនយោបាយទាំងអស់ដើម្បីរកវិធីសាស្ត្រដើម្បីបង្កើនការឃោសនា បណ្តុះបណ្តាល អប់រំ ដល់ប្រជាពលរដ្ឋ ការខ្វះខាតនឹងមើលទៅមិនអស់ទេ ប៉ុន្តែ PEC តាំងចិត្តថានិងបង្កើនដើម្បីឱ្យជ្រួតជ្រាបដល់ប្រជាពលរដ្ឋថែមទៀត ប៉ុន្តែក្នុងនេះក៏ខ្ញុំកត់សំគាល់ឃើញថាការអភិវឌ្ឍន៍នៃទឹកចិត្តប្រជាពលរដ្ឋក៏មានការកើនឡើងហើយ មិនមែនជាការថយចុះទេ បើតាមស្ថិតិប្រចាំឆ្នាំគឺក្នុងឆ្នាំ ២០០២ អ្នកដែលចូលរួមបោះឆ្នោតមាន ៦១.៦១៧ នាក់ ឆ្នាំ ២០០៣ ចុះឈ្មោះ ៨០.៤៩៩ នាក់ ដល់ ២០០៤ ក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះដែលមានស្រាប់នៅក្នុង PEC មាន ៨៣.០១៣ ឆ្នាំ ២០០៥ ដែលទើបតែធ្វើបញ្ជីស្រង់បញ្ជីឈ្មោះប្រចាំឆ្នាំនេះមាន ៨៤.៥៥៤ ដូចនេះបញ្ជីនេះឃើញតែឡើង នេះជាឆន្ទៈរបស់ប្រជាពលរដ្ឋដែលស្រឡាញ់លិទ្ធិប្រជាធិបតេយ្យក្នុងការបំពេញសិទ្ធិបោះឆ្នោត ។ ទាក់ទងនឹងអ្នកចុះឈ្មោះមានប្រជាពលរដ្ឋមិនចេះអក្សរ មើលមិនឃើញនោះ លោកបញ្ជាក់ថា មានការផ្សព្វផ្សាយតាមវិទ្យុសំរាប់ស្តាប់ ហើយបើដាក់ផ្ទាំងរូបភាពធំៗ PEC ខំប្រឹងធ្វើឱ្យអស់លទ្ធភាពបើថាខ្វះខាតយ៉ាងណាទៀតចាំរកវិធីថែមទៀត ។ តាមនីតិវិធីអ្នកយាមការិយាល័យមិនមានភារៈកិច្ចប្រាប់ឈ្មោះអ្នកបោះឆ្នោតទេ គាត់គ្រាន់តែយាមនៅទីនេះឱ្យចូលម្តងមួយៗ ដើម្បីកុំឱ្យចង្អៀតនៅកន្លែងបោះឆ្នោតតែប៉ុណ្ណោះ ។ អ្នកយាមមិនមានបញ្ជីឈ្មោះអ្នកបោះឆ្នោតទេ គាត់គ្រាន់តែថាកុំឱ្យចូលច្រើនពេក អ្នកមកក្រោយកុំអាលចូលរុលមកមុន ។ ចំពោះលទ្ធផលសំឡេងសេសសល់នេះវាហួសសមត្ថភាពរបស់លោក ព្រោះលោកគ្រាន់តែជាគណៈកម្មាការមួយអនុវត្តន៍ផែនការណ៍ទូទៅរបស់ គជប ។

លោក **ឱក សេរី សោភក្តិ៍** បានសរុបខ្លឹមសារសំខាន់ៗដែលបានពិភាក្សានៅព្រឹកនេះមានរហូតដល់ ១៥ ចំនុចដូចខាងក្រោមៈ

-ទី ១ របាយការណ៍របស់លោកប្រធាន PEC ក្រុងព្រះសីហនុ ជូនអង្គប្រជុំដើម្បីចាប់ផ្តើមការពិភាក្សា ។

-ទី ២ អង្គប្រជុំបានទទួលស្គាល់ថាបញ្ហាការផ្សព្វផ្សាយថ្វីត្បិតតែធ្វើបានល្អប្រសើរប្រកបដោយវិជ្ជមានច្រើនក៏ប៉ុន្តែនៅក្នុងលក្ខណៈនេះនៅមានការប្រឹងប្រែងដើម្បីឱ្យបានជ្រួតជ្រាបទៅដល់ប្រជាពលរដ្ឋជាពិសេសនៅតាមផ្ទះដាច់ស្រយាល ដែលនេះតោងមានការចូលរួម ពីតួអង្គផ្សេងៗទៀតនៅក្នុងយន្តការនៃការបោះឆ្នោត ។

-ទី ៣ អង្គប្រជុំបានទទួលស្គាល់ថាការចុះឈ្មោះបោះឆ្នោតនៅមានសេសសល់បញ្ហាខ្លះដែលគួរតែរួមគ្នាដោះស្រាយបាន ជាពិសេសទាក់ទងនឹងការដែលចុះឈ្មោះនៅកន្លែងផ្សេង បោះឆ្នោតនៅកន្លែងផ្សេង លោកប្រធាន PEC បានបញ្ជាក់ថានេះតំរូវការចាំបាច់នៅពេលដែលគិតពីកន្លែង ទីតាំងបានត្រូវផ្លាស់ប្តូរដោយសារមានសភាពការណ៍ចាំបាច់ ក៏ប៉ុន្តែគួរតែធ្វើយ៉ាងណាអាចសំរួលដល់ប្រជាពលរដ្ឋជាអ្នកបោះឆ្នោត ។ នៅពេលដែលប្តូរការិយាល័យបោះឆ្នោតសូមឱ្យប្រឹងប្រែងជាពិសេសជូនព័ត៌មានពីការផ្លាស់ប្តូរនេះ ទៅដល់អ្នកបោះឆ្នោតឱ្យទាន់ពេលវេលា ហើយឱ្យបានទូលំទូលាយ ។

-ទី ៤ អង្គប្រជុំបានទទួលស្គាល់ថាការប្រឹងប្រែងអប់រំដល់ប្រជាពលរដ្ឋអ្នកបោះឆ្នោត គឺជាការចាំបាច់ណាស់បើមិនដូចនេះទេនិងបាត់បង់ការយកចិត្តទុកដាក់នៅក្នុងយន្តការនៃការបោះឆ្នោត ដែលគួរតែមានការចូលរួមគ្នាទប់ស្កាត់ការធ្លាក់ចុះនេះ និងពង្រឹងការអប់រំ ពញ្វាក់ស្មារតីប្រជាពលរដ្ឋឱ្យមានការចូលរួមខ្លាំងក្លាជាងនេះ ។

-ទី ៥ មានការជជែកវែកញែកខ្លះអំពីការបោះឆ្នោតព្រឹទ្ធសភាជាពិសេសខាងគណបក្សសមរង្ស៊ី បានទទួលស្គាល់ថាការបោះឆ្នោតនេះហាក់ដូចជាដឹងលទ្ធផលមុន ដូច្នេះនឹងពិនិត្យមើលថាតើក្រោយៗទៀតនិងមានការកែប្រែច្បាប់នេះ ទាក់ទងទៅនិងប្រពន្ធ័នៃការបោះឆ្នោត ឬរបៀបរបបនៃការបោះឆ្នោត ។

-ទី ៦ មានសំណើថាតើតួនាទីរបស់កងប្រដាប់អាវុធគួរធ្វើពិចារណាវិញ ព្រោះទាំងកងឯកភាពទាំងកងកំលាំងប្រដាប់អាវុធ នៅពេលបោះឆ្នោតជាក្រុមច្រើនបោះឆ្នោតតាមបញ្ជារបស់បញ្ជាការ ។

-ទី ៧ អង្គប្រជុំបានទទួលស្គាល់ថាជាដំណឹងមួយដែលថាការរាប់សន្លឹកឆ្នោតមិនច្របល់បញ្ចូលគ្នា ពិសេសនៅតំបន់រាមនៅពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំ ២០០៣ ដែលតំរូវឱ្យបញ្ចូលគ្នាទើបរាប់ មិនមែនរាប់នៅកន្លែងបោះឆ្នោតទេ ។ លោកប្រធាន PEC នឹងធ្វើការសិក្សាអំពីរឿងនេះដើម្បីស្វែងរកការពិតថាតើកើតឡើងយ៉ាងម៉េចបាន ព្រោះខុសនីតិវិធីរបស់ គជប យើងនិងធ្វើការត្រួតពិនិត្យរឿងនេះឡើងវិញទាំងអស់ គ្នានេះជាដំណឹងពិសេសដែលយើងបានទទួល។

-ទី ៨ មានសំណូមពរថាសូមឱ្យបន្ថែមពេលវេលាពីម៉ោង ៣ នៃការបញ្ចប់ការបោះឆ្នោតទៅម៉ោង ៥ ។ ខប់សែលនឹងនាំយកសំណើនេះលើកទៅថ្នាក់ជាតិ ហើយនឹងគិតថាបើសិនជា បន្ថែមម៉ោងមិនបាន តើមានលទ្ធភាពអាចបង្កើនការិយាល័យបោះឆ្នោតផ្សេងៗទៀត ដែលតំរឹមទៅនិងស្ថានការណ៍ភូមិសាស្ត្រជាក់ស្តែងនៅទីក្រុងព្រះសីហនុនេះ ។

-ទី ៩ មានការលើកឡើងថាការជ្រើសរើសមន្ត្រី CEC នៅតាមឃុំនៅមានខ្វះតម្លាភាព ។ លោក ប្រធាន PECបានឆ្លើយបញ្ជាក់នៅក្នុងរឿងនេះ ហើយនឹងខំប្រឹងធ្វើយ៉ាងណាដើម្បីឱ្យយន្តការនៃការរើស មន្ត្រីនៅថ្នាក់ឃុំនេះបានប្រសើរឡើងជាងមុនទៅតាមក្រិត្យក្រមរបស់ គជប ។

-ទី ១០ មានសំណូមពរថាសូមឱ្យមានធ្វើវិសោធនកម្មនីតិវិធី និងច្បាប់ដែលទាក់ទងនិងការបោះឆ្នោត ។ លោកបានជំរាបជូនអង្គប្រជុំថាបញ្ហានេះនៅថ្នាក់ជាតិកំពុងតែពិនិត្យ ពិសេសនៅពេលប្រជុំខប់សែលខមខែក្រោយនេះ នឹងមានលើកយកច្បាប់បោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ២០០៧ និងថ្នាក់ជាតិ ២០០៨ ដើម្បីពិនិត្យឡើងវិញដោយអ្នកបច្ចេកទេសច្បាប់ រួមជាមួយ គជប ថាតើកន្លែងណាខ្លះដែលអាចស្នើទៅក្រសួងមហាផ្ទៃ សុំឱ្យមានធ្វើវិសោធនកម្មច្បាប់ ។ នៅខែ មិនា ២០០៦ គជប នឹងធ្វើការប្រជុំសរុបទូទាំងប្រទេស ពេលនោះហើយដែលសំណើទាំងឡាយអាចលើកឡើងនៅក្នុង ការប្រជុំសំខាន់នេះ។

-ទី ១១ ទាក់ទងនឹងយុទ្ធនាការឃោសនាបោះឆ្នោតនៅទីក្រុងព្រះសីហនុមាន ការជឿនលឿនច្រើន ហើយគ្រាន់តែស្នើសុំឱ្យមានការគោរពគ្នាទៅវិញទៅមក និងគោរពតាមក្រឹតក្រមសីលធម៌ដែលបានអនុម័តឡើងដោយ គជប ។

-ទី ១២ មានការស្នើសុំឱ្យសិក្សាថា តើគួរប្តូរកាលបរិច្ឆេទនៃការបោះឆ្នោតពីខែ ៧ ទៅខែផ្សេងៗបានទេ ដោយសារខែ ៧ នេះមានភ្លៀងធ្លាក់ច្រើន ហើយកសិករចាប់ផ្តើមរវល់ធ្វើស្រែចំការ ។

-ទី ១៣ បញ្ហាបានលើកឡើងទាក់ទងនឹងរូបមន្តនៃការរាប់សន្លឹកឆ្នោត ដើម្បីកំណត់យកកៅអី ដោយមានការស្នើសុំឱ្យពិចារណាថាតើគួរកែប្រែរូបមន្តនេះដូចជិនាន់អ៊ុនតាក់ ។

-ទី ១៤ ពេលចុះឈ្មោះបោះឆ្នោតរបស់កម្មកររោងចក្រមានជួបការលំបាកឈប់សំរាក ពេលទៅបោះឆ្នោតក៏លំបាកសុំច្បាប់ បើសុំច្បាប់ទៅលើសថៅកែកាត់លុយរហូតដល់ដេញចោលថែមទៀត ។ បញ្ហានេះជាការបារម្ភរបស់ គជប និងរបស់តួអង្គផ្សេងៗទៀតនៅថ្នាក់ជាតិទាំងមូល ហើយមិនមែនទាក់ទងតែកម្មករនៅទីក្រុងព្រះសីហនុទេ គឺទាក់ទងនឹងកម្មករដែលមានចំនួន ២ សែន ៥ ម៉ឺននាក់នៅទូទាំងព្រះរាជណាចក្រកម្ពុជាមានបញ្ហានេះ ដូចៗគ្នាទាំងអស់ ។

-ទី ១៥ មានសំណើថាគួរធ្វើការរួមគ្នាឱ្យមានរបៀបរៀបរយនៅថ្ងៃបោះឆ្នោត កុំឱ្យមានការពពាក់ពពូននាំឱ្យ ពិបាកមើលឈ្មោះ និងគួររៀបចំឱ្យមានសណ្តាប់ធ្នាប់ឱ្យមានរបៀបរៀបរយល្អនៅថ្ងៃបោះឆ្នោត។